អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-May-2021, 13:03
CMS/CFO: Sann Rada

**អង្គបុរេជំនុំជម្រះ**

**អនុស្សរណៈអន្តរការិយាល័យ**

**ជូនចំពោះ៖ ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល** ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១

**ពី៖ ចៅក្រមអង្គបុរេជំនុំជម្រះ**

**កម្មវត្ថុ៖ ឯកសារសម្ងាត់ និងឯកសារកោសលប់ជាសាធារណៈ នៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានស្នើឲ្យចាត់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ**

១. អង្គបុរេជំនុំជម្រះ បានកំណត់សេចក្ដីសម្រេចសម្ងាត់ចំនួន ៩៧ និងដីកាសម្ងាត់ចំនួន ៥៤ របស់អង្គបុរេជំនុំជម្រះ សេចក្ដីសម្រេចសម្ងាត់ចំនួន ១៣៦ និងដីកាសម្ងាត់ចំនួន ២៥១ របស់សហចៅក្រមស៊ើបអង្កេត សេចក្ដីសម្រេចកោសលប់ជាសាធារណៈចំនួន ១៧ របស់អង្គបុរេជំនុំជម្រះ និងសេចក្ដីសម្រេចកោសលប់ជាសាធារណៈចំនួន ០១ និងដីកាកោសលប់ជាសាធារណៈចំនួន ០៧ របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០២[1]។

២. បន្ទាប់ពីបានពិនិត្យមើលយ៉ាងប្រុងប្រយ័ត្នទៅលើឯកសារទាំងអស់នេះរួចមក អង្គបុរេជំនុំជម្រះពិចារណាថា ការចាត់ចំណាត់ថ្នាក់ជាសម្ងាត់ ឬកោសលប់ជាសាធារណៈចំពោះឯកសារទាំងនេះ គឺលែងសមស្របទៀតហើយ នៅកិច្ចដំណើរការនីតិវិធីដំណាក់កាលនេះ។

[1] សូមមើលឧបសម្ព័ន្ធ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

៣. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ផ្ដល់នូវមតិយោបល់អំពីភាពចាំបាច់បន្តទៀត សម្រាប់ការរក្សាការសម្ងាត់នៃឯកសារទាំងអស់នេះ នៅដំណាក់នេះក្នុងសំណុំរឿង ០០២ ហើយអង្គបុរេជំនុំជម្រះស្នើចាត់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ អនុលោមតាមមាត្រា ៩.១ និង ១២.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ដោយមានការលើកលែងចំពោះឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនរបស់សាក្សី ដែលស្ថិតក្រោមវិធានការការពារ ឬដែលសំណើសុំវិធានការការពាររបស់ពួកគាត់ កំពុងរង់ចាំសេចក្ដីសម្រេចដែលត្រូវរក្សាជាការសម្ងាត់បន្ត[2]។

[2] សូមមើលសំណុំរឿង ០០៤/១ (អបជ៤៩) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលប់ ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ នៃដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D309/2/1/7, សំណុំរឿង ០០៤/១ (អបជ ៥៤) សេចក្ដីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D304/6/4។